សាលាដំបូង
ខេត្តបន្ទាយមានជ័យ
-សំណុំរឿងរដ្ឋប្បវេណីលេខ: ៤៨៤ ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០២០
-សាលក្រមរដ្ឋប្បវេណីលេខ: ៥"ឃ"/៣៦ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ .

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តបន្ទាយមានជ័យ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ ។

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តបន្ទាយមានជ័យ

**-រវាងដើមចោទ** ឈ្មោះ [redacted] **សុគន្ធា** ភេទស្រី អាយុ ៣៤ឆ្នាំ សញ្ជាតិ ខ្មែរ មុខរបរ កសិករ មានទីលំនៅសព្វថ្ងៃនៅភូមិ [redacted] ។

មានលោកមេធាវី [redacted] អត្តលេខ៖ ២០១៤T និងលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិ ។

**- និងចុងចម្លើយ** ឈ្មោះ [redacted] **គឹមយ៉ុង** ភេទប្រុស អាយុ ៣៦ឆ្នាំ សញ្ជាតិ ខ្មែរ មុខរបរ កសិករ មានទីលំនៅសព្វថ្ងៃនៅ [redacted] ។

ដែលមានកម្មវត្ថុបណ្តឹង៖ **ដើមចោទសុំផ្តាច់អនីតិសង្វាសពីចុងចម្លើយ** ។

**អង្គហេតុ និងចំណុចវិវាទ**

*ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ:*

១-ផ្តាច់ការរស់នៅតាមបែបអនីតិសង្វាសរវាងដើមចោទ និងចុងចម្លើយ ។

២-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] **គឹមយ៉ុង** ប្រគល់ដីស្រែ ០១ហិចតាកន្លះ និងដីចំការដំឡូង កន្លះហិចតា មកឲ្យដើមចោទឈ្មោះ [redacted] សុគន្ធា ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

*ខ.ដំណើររឿងក្តី និងចំណុចវិវាទ*

*ខ.១.ការសង្ខេបអំពីរឿងក្តី*

តាមពាក្យបណ្តឹងចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ ដើមចោទឈ្មោះ [redacted] សុគន្ធា បានទាមទារឲ្យ



Scanned with CamScanner

តុលាការចេញសាលក្រមដែលមានខ្លឹមសារសម្រេច៖ ១-ផ្តាច់ការរស់នៅតាមបែបអនីតិសង្វាសរវាងដើមចោទ និងចុងចម្លើយ ។ ២-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] គឹមយ៉ុង ប្រគល់ដីស្រែ ០១ហិចតាកន្លះ និងដីចំការដំឡូងកន្លះហិចតា មកឱ្យដើមចោទឈ្មោះ [redacted] សុគន្ធា ។ ៣-ឱ្យប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។ ប៉ុន្តែបន្ទាប់ពីផ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទបានសុំលះបង់ការទាមទារចំណុចទី២.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] គឹមយ៉ុង ប្រគល់ដីស្រែ ០១ហិចតាកន្លះ និងដី ចំការដំឡូង កន្លះហិចតា មកឱ្យដើមចោទឈ្មោះ [redacted] សុគន្ធា ចោលវិញ ដោយហេតុថា ដីស្រែ និងដីចំការនេះ មិនមែនជាទ្រព្យសម្បត្តិរួមរវាងខ្លួន និងចុងចម្លើយ គឺជាទ្រព្យសម្បត្តិរបស់ឪពុកម្តាយចុងចម្លើយដែលបានប្រគល់ឱ្យខ្លួន និងចុងចម្លើយប្រើប្រាស់ និងអាស្រ័យផលប៉ុណ្ណោះ ។ ចំណែកឯមូលហេតុដែលដើមចោទទាមទារលែងលះពីចុងចម្លើយដោយហេតុថា មានការរស់នៅមិនចុះសម្រុងគ្នា មានការឈ្លោះប្រកែកគ្នា មានការរស់នៅបែកលំនៅសង្វាសគ្នា និងអស់មនោសញ្ចេតនា នឹងគ្នា ។

តាមសេចក្តីថ្លែងការណ៍របស់ដើមចោទនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់ឃើញថា ចុងចម្លើយឈ្មោះ [redacted] គឹមយ៉ុង បានអះអាងថា ខ្លួនមិនព្រមលែងពីដើមចោទឈ្មោះ [redacted] សុគន្ធា នោះទេ ព្រោះថា ខ្លួននៅស្រឡាញ់ប្រពន្ធមិនចង់បែកបាក់ពីប្រពន្ធ ហើយខ្លួនក៏មិនបានដើរលេង ឬធ្វើបាបអ្វីទៅលើ ប្រពន្ធដែរ ។

### *១.២.អង្គហេតុដែលគ្មានវិវាទ*

គ្មាន ។

### *១.៣.ចំណុចមានវិវាទ*

តើមានមូលហេតុនៃការផ្តាច់ការរស់នៅតាមបែបអនីតិសង្វាសរវាងដើមចោទ និងចុងចម្លើយដែរឬទេ?

### *១.៤.ការអះអាងរបស់ភាគីពាក់ព័ន្ធនឹងចំណុចវិវាទ*

#### *១.៤.១.ការអះអាងរបស់ដើមចោទ*

ដើមចោទឈ្មោះ [redacted] សុគន្ធា សុំប្តឹងទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារសម្រេច៖ ផ្តាច់ការរស់នៅតាមបែបអនីតិសង្វាសរវាងខ្លួន និងចុងចម្លើយ និងឱ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។ ដោយសារមូលហេតុ មានការរស់នៅមិនចុះសម្រុងគ្នា មានការឈ្លោះប្រកែកគ្នាមានការរស់នៅបែកលំនៅសង្វាសគ្នា និងអស់មនោសញ្ចេតនានឹងគ្នា ។ ចំពោះការទាមទារចំណុចទី២.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] គឹមយ៉ុង ប្រគល់ដីស្រែ ០១ហិចតាកន្លះ និងដី ចំការដំឡូង កន្លះហិចតា មកឱ្យខ្លួន ខ្លួនសុំលះបង់ការទាមទារចោលវិញ ដោយហេតុថា ដីស្រែ និងដីចំការនេះ មិនមែនជាទ្រព្យសម្បត្តិរួមរវាងខ្លួន និងចុងចម្លើយ គឺជាទ្រព្យសម្បត្តិរបស់ឪពុកម្តាយចុងចម្លើយដែលបានប្រគល់ឱ្យខ្លួន និងចុងចម្លើយប្រើប្រាស់ និងអាស្រ័យផលប៉ុណ្ណោះ ។

## ខ.៤.២.ខ្លឹមសារនៃសេចក្តីថ្លែងការណ៍របស់ចុងចម្លើយ

ចុងចម្លើយឈ្មោះ [redacted] **គឹមយ៉ុង** បានអះអាងថា ខ្លួនមិនព្រមលែងពី ដើមចោទឈ្មោះ [redacted] សុគន្ធា នោះទេ ព្រោះថា ខ្លួននៅស្រឡាញ់ប្រពន្ធមិនចង់បែកបាក់ពីប្រពន្ធ ហើយខ្លួនក៏មិនបានដើរលេង ឬធ្វើបាបអ្វីទៅលើប្រពន្ធដែរ ។ ចំពោះដីស្រែ និងដីចំការដែលដើមចោទទាមទារ គឺពិតជាទ្រព្យសម្បត្តិរបស់ឪពុកម្តាយខ្លួនប្រាកដមែន មិនមែនជាទ្រព្យសម្បត្តិរួមរវាងខ្លួន និងដើមចោទនោះទេ ។

## សំអាងហេតុ

**ក.ស្តីពីចំណុចវិវាទ (មូលហេតុនៃការផ្តាច់អនីតិសង្វាសរវាងដើមចោទ និងចុងចម្លើយ)**

-ដើមចោទឈ្មោះ [redacted] **សុគន្ធា** បានទាមទារផ្តាច់ការរស់នៅតាមបែបអនីតិសង្វាសជាមួយនឹងចុងចម្លើយឈ្មោះ [redacted] **គឹមយ៉ុង** ។ ប៉ុន្តែចុងចម្លើយមិនយល់ព្រមផ្តាច់ការរស់នៅតាមបែបអនីតិសង្វាសជាមួយនឹងចុងចម្លើយ តាមការទាមទាររបស់ចុងចម្លើយនោះទេ ។

-តាមសេចក្តីថ្លែងការណ៍គូភាគីនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឃើញថា៖ ដើមចោទ និងចុងចម្លើយពិតជាមានការរស់នៅបែកលំនៅឋានគ្នា មានការរស់នៅមិនចុះសម្រុងគ្នា មានការឈ្លោះប្រកែកគ្នា និងអស់មនោសញ្ចេតនានឹងគ្នា ប្រាកដមែន គឺជាមូលហេតុនៃការផ្តាច់អនីតិសង្វាស ។

**ខ.ស្តីពីការទាមទារចំណុចទី២ (ការទាមទារទ្រព្យសម្បត្តិរួម)**

-តាមពាក្យបណ្តឹង ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ ឃើញថា ដើមចោទបានទាមទារឱ្យចុងចម្លើយប្រគល់ដីស្រែ ០១ហិចតាកន្លះ និងដី ចំការដំឡូងកន្លះហិចតា មកឱ្យខ្លួន ។ ប៉ុន្តែបន្ទាប់ពីឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទបានលះបង់ការទាមទាររបស់ខ្លួនចោលវិញ ដោយហេតុថា ដីនេះមិនមែនជាទ្រព្យសម្បត្តិរួមរវាងខ្លួន និងចុងចម្លើយនោះទេ គឺជាទ្រព្យសម្បត្តិរបស់ឪពុកម្តាយចុងចម្លើយ មិនមានការពាក់ព័ន្ធនឹងខ្លួន និងចុងចម្លើយនោះទេ ។

-ចុងចម្លើយបានអះអាងថា ដីស្រែ និងដីចំការដែលដើមចោទទាមទារខាងលើ គឺពិតជាទ្រព្យសម្បត្តិរបស់ឪពុកម្តាយខ្លួនប្រាកដមែន មិនមែនជាទ្រព្យសម្បត្តិរួមរបស់ខ្លួន និងដើមចោទនោះទេ ។

**គ.ការវិនិច្ឆ័យអំពីការទាមទារ**

-ការរួមរស់នៅជាមួយគ្នារវាងដើមចោទ និងចុងចម្លើយ មានការមិនចុះសម្រុងគ្នា មានការឈ្លោះប្រកែកគ្នា អស់មនោសញ្ចេតនានឹងគ្នា និងមានការរស់នៅបែកលំនៅសង្វាស ។ ហេតុដូចនេះ គប្បីតុលាការសម្រេចផ្តាច់ការរស់នៅតាមបែបអនីតិសង្វាសរវាងដើមចោទ និងចុងចម្លើយ ។

-ចំពោះការទាមទារចំណុចទី២.ដើមចោទបានទាមទារឱ្យចុងចម្លើយ ប្រគល់ដីស្រែ ០១ហិចតាកន្លះ និងដីចំការដំឡូងកន្លះហិចតាមកឱ្យខ្លួននោះ ដើមចោទបានលះបង់ការទាមទារវិញហើយ ។ ហេតុដូច្នេះ គប្បីតុលាការមិនយកមកពិចារណាសម្រេចនៅក្នុងសាលក្រមនោះទេ ផ្អែកតាមមាត្រា១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។



Scanned with CamScanner

**ឃ.ស្ដីពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី**

ប្រាក់ប្រដាប់ក្ដី គប្បីតុលាការសម្រេចឱ្យដើមចោទ និងចុងចម្លើយជាអ្នកទទួលបន្ទុកស្មើៗគ្នា ស្របតាមមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## <u>សេចក្ដីសម្រេចបញ្ចប់</u>

១/.ផ្ដាច់ការរស់នៅតាមបែបអនីសង្វាសរវាងដើមចោទឈ្មោះ [redacted] សុគន្ធា និងចុងចម្លើយឈ្មោះ [redacted]គីមយ៉ុង ចាប់ពីពេលនេះតទៅ ។

២/.ឱ្យដើមចោទ និងចុងចម្លើយជាអ្នកទទួលបន្ទុកស្មើៗគ្នានូវប្រាក់ប្រដាប់ក្ដីតុលាការ ។

សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ ចំពោះមុខដើមចោទ និងមុខចុងចម្លើយ ។

ទុកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍តាមការកំណត់ច្បាប់ ។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ០៥កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

បន្ទាយមានជ័យ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១

បានឃើញ

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner